# ព្រះរាជក្រម

នស/រកម/០៧០២/០១៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទី២ ២០០១-២០០៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍
## សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២ ២០០១-២០០៥

**មាត្រា ១.-**

អនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី ២ ២០០១-២០០៥ ដូចមានឯកសារភ្ជាប់មកជាមួយ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តអនុវត្តផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី ២ ២០០១-២០០៥ នេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

ករស.០៧.០៧.០០២៥៣ **ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម រណឫទ្ធិ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ហត្ថលេខា**

**ឆាយ ថន**

លេខ: ១៧៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃាធី តាន់**